ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
លេខ : ៤៣៣ សរ.សណ. សកទ

ថ្ងៃ អង្គារ ៨កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ២០២០

# សេចក្តីជូនដំណឹង
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី
# ថ្ងៃអង្គារ ៨កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
# ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០

កាលពីថ្ងៃអង្គារ ៨កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាពនៃទីស្តីការគណៈរដ្ឋមន្ត្រី មានបើកសម័យប្រជុំគណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖

១- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន។

២- បញ្ហាផ្សេងៗ។

## ១- សេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន

គណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី បានពិនិត្យនិងកែសម្រួលលើខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះមានជាអាទិ៍៖

- មាត្រា៣ ត្រូវពិនិត្យនិងកែសម្រួលបន្ថែមខ្លឹមសារអំពី៖
  - ការកំណត់ថិរវេលាកំណត់សម្រាប់ការប្រកាសដាក់ប្រទេសជាតិស្ថិតនៅក្នុងភាពអាសន្នមិនឱ្យលើសពី៣ខែ ហើយថិរវេលានេះអាចត្រូវបានបន្តក្នុងលក្ខខណ្ឌដូចគ្នា
  - ការកំណត់បែបបទនិងនីតិវិធីនៃការបញ្ចប់កាលៈទេសៈពិសេសនេះ ដើម្បីឱ្យស្របតាមមាត្រា៨៦ និងមាត្រា១០២ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទំព័រ ២

- មាត្រា៩ ត្រង់កថាខណ្ឌចុងក្រោយ បានកែសម្រួលទៅជា «ក្នុងពេលសង្គ្រាម ឬក្នុងកាលៈទេសៈដទៃទៀតដែលសន្តិសុខជាតិប្រឈមមុខនឹងគ្រោះថ្នាក់ធ្ងន់ធ្ងរ ការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្នដោយរាជរដ្ឋាភិបាលអាចធ្វើឡើងតាមរបបអាជ្ញាសឹក។»
- បន្ថែមមាត្រាមួយថ្មីនៅក្នុងជំពូកទី៤ ស្តីពីទោសប្បញ្ញត្តិ ដូចខាងក្រោម៖

  «មាត្រា១០- ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ច

  អាជ្ញាធរមានសមត្ថកិច្ចដែលប្រើប្រាស់សិទ្ធិអំណាចដោយរំលោភ ដើម្បីធ្វើតាមទំនើងចិត្ត ហើយបង្កការខូចខាតដល់រូបរាងកាយ ឬទ្រព្យសម្បត្តិអ្នកដទៃ ត្រូវទទួលខុសត្រូវចំពោះអំពើដែលខ្លួនបានប្រព្រឹត្ត។»

គណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រីបានសម្រេចប្រគល់ភារកិច្ចជូនឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដោយមានការចូលរួមពីក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងមហាផ្ទៃ ពិនិត្យនិងកែសម្រួលលើសេចក្តីព្រាងច្បាប់នេះតាមការសម្រេចរបស់អង្គប្រជុំ។

គណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រី បានសម្រេចឯកភាពបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ដែលបានកែសម្រួលខ្លឹមសារ ពាក្យពេចន៍ និងអក្ខរាវិរុទ្ធតាមស្មារតីអង្គប្រជុំរួច ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ ដោយមិនដាក់ឆ្លងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីទៀតទេ ហើយចាត់ឯកឧត្តម **កើត រិទ្ធ** រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអ្នកការពារសេចក្តីព្រាងច្បាប់នេះនៅស្ថាប័ននីតិប្បញ្ញត្តិ។

## ២- បញ្ហាផ្សេងៗ

គណៈអចិន្ត្រៃយ៍គណៈរដ្ឋមន្ត្រីបានសម្រេច៖

២.១- អនុញ្ញាតជូនឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន** ឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មានចំណារក្នុងនាម **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** លើរបាយការណ៍ ឬឯកសារមួយចំនួនរបស់ក្រសួងស្ថាប័ននានាដែលបានដាក់មកទីស្តីការគណៈរដ្ឋមន្ត្រី ឬដាក់ជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** លើកលែងតែឯកសារដែលស្នើសុំយោបល់ឬការសម្រេចពី**សម្តេចតេជោ នាយករដ្ឋមន្ត្រី**។

២.២- ប្រគល់ភារកិច្ចជូនសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ធ្វើការបន្ថែមសមាសភាព ឯកឧត្តមទេសរដ្ឋមន្ត្រី **អង្គ វង្សវឌ្ឍានា**

ឯកឧត្តមទេសរដ្ឋមន្ត្រី **ពេជ្រ ប៊ុនធិន** និងឯកឧត្តម **ផាំ សុខា** រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ទៅក្នុងគណៈកម្មាធិការជាតិនេះ។

២.៣- ក្នុងកាលៈទេសៈដ៏លំបាកនៃការរីករាលដាលការឆ្លងវីរុសកូវីដ-១៩ ត្រូវជំរុញវិស័យកសិកម្មក្នុងស្រុកដែលជាចំណុចខ្លាំងរបស់កម្ពុជា ហើយត្រូវស្តុកបម្រុងទុកនូវទំនិញយុទ្ធសាស្ត្រ ដូចជា អង្ករ និងអំបិល។ ការផ្អាកការនាំចេញស្រូវនិងអង្ករ ស លើកលែងតែអង្ករក្រអូប ត្រូវអនុវត្តចាប់ពីថ្ងៃទី៥ ខែមេសា ឆ្នាំ២០២០ រហូតដល់មានវិធានការជាថ្មី។ ទន្ទឹមនឹងនេះ ត្រូវត្រៀមទំនិញយុទ្ធសាស្ត្រផ្នែកសុខាភិបាល ដូចជា ម៉ាស់ ទឹកអាល់កុល សំលៀកបំពាក់ការពារសម្រាប់គ្រូពេទ្យ។

២.៤- ចាត់ទុកអាល់កុល និងម៉ាស់ជាទំនិញយុទ្ធសាស្ត្រ សម្រាប់បម្រុងទុកប្រើប្រាស់ក្នុងកាលៈទេសៈនៃការរីករាលដាលនៃវីរុសកូវីដ-១៩។ រាជរដ្ឋាភិបាលបានសម្រេចបញ្ជាទិញម៉ាស់ ចំនួន ៥លាន ២សែន ក្នុងនោះ ពីក្រៅប្រទេសមានចំនួន ៤លាន និង ពីរោងចក្រផលិតម៉ាស់នៅខេត្តព្រះសីហនុ ចំនួន ១លាន ២សែន ដើម្បីត្រៀមចែកជូនប្រជាពលរដ្ឋ និងផ្តល់ជូនមន្ទីរពេទ្យមួយចំនួន។ ជាងនេះទៅទៀត ក្រៅពីសំលៀកបំពាក់ពេទ្យដែលត្រូវបានផលិតនៅខេត្តស្វាយរៀង រាជរដ្ឋាភិបាលក៏បានបញ្ជាទិញម៉ាស់សម្រាប់គ្រូពេទ្យចំនួនជាង ២០ម៉ឺន បន្ថែមទៀត ដើម្បីបម្រើឱ្យសេចក្តីត្រូវការខាងផ្នែកវេជ្ជសាស្ត្រនាពេលខាងមុខ។ រាជរដ្ឋាភិបាលមានគោលដៅប្រែក្លាយរោងចក្រមួយចំនួនទៅជាផលិតម៉ាស់ អាល់កុល និងសម្ភារៈបរិក្ខារវេជ្ជសាស្ត្រសម្រាប់ផ្គត់ផ្គង់ទៅឱ្យរដ្ឋ ដើម្បីប្រើប្រាស់នៅក្នុងស្រុកតែម្តង។

២.៥- បញ្ជាក់សាជាថ្មីម្តងទៀតថា ជំនួយឧបត្ថម្ភពីសប្បុរសជននឹងមិនត្រូវយកមកផ្គត់ផ្គង់បុគ្គលិកសុខាភិបាលឡើយ តែត្រូវយកទៅទិញសម្ភារៈបរិក្ខារផ្សេងៗ ជាអាទិ៍ ម៉ាស់ និងអាល់កុលសម្រាប់ចែកជូនប្រជាជនវិញ។

២.៦- ក្រើនរំលឹកដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងប្រព័ន្ធផ្សព្វផ្សាយទាំងអស់ឱ្យបន្តជួយផ្សព្វផ្សាយសារអប់រំស្តីពីការការពារជំងឺបង្កដោយវីរុសកូវីដ-១៩។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានណែនាំជាថ្មីម្តងទៀតឱ្យអាជ្ញាធរពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់ទាំងអស់ ជាពិសេសអាជ្ញាធរ មូលដ្ឋានត្រូវតែគ្រប់គ្រងឱ្យបានម៉ត់ចត់ និងបន្តតាមដានស្ថានភាពសុខភាពរបស់ពលករខ្មែរទាំងឡាយដែលទើបមកពីបរទេស។

២.៧- ចំពោះការរៀបចំសេចក្តីព្រាងច្បាប់ថ្មីៗនាពេលខាងមុខ ត្រូវរៀបចំជាទម្រង់ដែលមានមាត្រាចែងអំពីគោលបំណង បានហើយ ដោយមិនចាំបាច់មានមាត្រាចែងអំពីគោលដៅទេ។

២.៨- ប្រគល់ភារកិច្ចជូនក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ត្រៀមលក្ខណៈដើម្បីពិគ្រោះយោបល់ជាមួយសហភាពអឺរ៉ុបនិងបណ្តាប្រទេសមួយចំនួនទៀត អំពីលទ្ធភាពនៃការលើកពេលប្រជុំកំពូលអាស៊ីអឺរ៉ុប ឆ្នាំ២០២០ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះទៅឆ្នាំ២០២១វិញ។

ទទួលបានសេចក្តីជូនដំណឹងនេះ គ្រប់ក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត ពាក់ព័ន្ធត្រូវយកចិត្តទុកដាក់អនុវត្តឱ្យទទួលបានលទ្ធផលជាវិជ្ជមាន។

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ចម្លងជូន ៖**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ